# ព្រះវិហារល្អប្លែកនៅវត្តកំពូល

វត្តកំពូល ឬវត្តទីបារាម ស្ថិតនៅក្នុងឃុំកោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដែលបានកសាងឡើងនៅប្របនឹងដងទន្លេធំ(ទន្លេមេគង្គ) ដូចបណ្តាវត្តបុរាណផ្សេងទៀតគឺវត្តកណ្តាល និងវត្តស្វាយសាច់ភ្នំជាដើម។ ប៉ុន្តែគេយល់ថាព្រះវិហារវត្តកំពូលគឺជាសំណង់ចាស់មួយក្នុងតំបន់ ដែលសង់ឡើងនៅលើខឿនបួនជ្រុងស្មើ មានដំបូលកំពូលត្រដួចឡើងតូចធំតាមថ្នាក់ចំនួន១៣ ហើយជាលក្ខណៈល្អប្លែកគេក្នុងសំណង់ព្រះវិហារព្រះពុទ្ធសាសនា។ អ្នកស្រាវជ្រាវ *Daniell Guéret* និង *Dominique-Pierre Guéret* បញ្ជាក់ថា ព្រះវិហារវត្តកំពូលកសាងឡើងក្នុងឆ្នាំ១៨៩៨(រូបលេខ១)។[1] ដូច្នេះបើគិតមកដល់សព្វថ្ងៃ ព្រះវិហារវត្តកំពូលមានអាយុកាល១២៦ឆ្នាំ។



*រូបលេខ១ ស្ថានភាពព្រះវិហារវត្តកំពូល មើលពីទិសពាយ័ព្យ (រូបថតឆ្នាំ២០២៣)*

[1] Daniell Guéret & Dominique-Pierre Guéret 2017: 110

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## *អត្ថបទ៖ ព្រះវិហារល្អប្លែកនៅវត្តកំពូល*

*បើផ្អែកតាមរូបថតឯកសារសាលាបារាំងចុងបូព៌ាប្រទេស (EFEO) ថតកាលពីឆ្នាំ ១៩២៩ បានឱ្យយើងកត់សម្គាល់ឃើញថា ព្រះវិហារវត្តកំពូលកសាងឡើងនៅលើខឿន ២ថ្នាក់ ដែលខឿនខាងក្រោមបំផុតមានកម្ពស់ប្រហែល១ម៉ែត្រ និងមានខ្លោងទ្វារចូលនៅតាមជ្រុងទាំង៤។ ចំពោះតួព្រះវិហារស្ថិតនៅលើខឿនទី២ ដែលមានកម្ពស់ប្រហែលត្រឹមដើមទ្រូង និងមានបង្កាន់ដៃជាប់នឹងសសរបាំងសាចព័ទ្ធជុំវិញ។ នៅផ្នែកខាងមុខនិងខាងក្រោយមានជណ្ដើរឡើងចូលព្រះវិហារ តែនៅផ្នែកចំហៀងពុំមានជណ្ដើរឡើយ។ រីឯដំបូលព្រះវិហារប្រក់ក្បឿងស្រកាលេញ មានរាងជាថ្នាក់ៗ ហើយនៅតាមចុងថែងដំបូលគេលម្អដោយកំពូលទម្រង់ដូចកំពូលចេតិយ ព័ទ្ធជុំវិញកំពូលកណ្ដាលដែលមានទំហំធំជាងគេ (រូបលេខ២)។ លក្ខណៈស្ថាបត្យកម្មព្រះវិហារនេះ គេសង្កេតឃើញនៅរក្សាទម្រង់ដើមស្ទើរទាំងស្រុងរហូតដល់សព្វថ្ងៃ លើកលែងតែខឿនខាងក្រោមបំផុតដែលពុំមានខ្លោងទ្វារតាមជ្រុងនីមួយៗ ហើយបានរៀបចំជាបង្កាន់ដៃនាគព័ទ្ធជុំវិញ និងមានជណ្ដើរឡើងតាមទិសទាំង៤ (រូបលេខ៣)។*



***រូបលេខ២-៣ ព្រះវិហារវត្តកំពូលថតឆ្នាំ១៩២៩ (ប្រភព៖ EFEO) ព្រះវិហារវត្តកំពូលថតឆ្នាំ២០២៣***

*ជាការពិត រហូតមកដល់សព្វថ្ងៃនេះគេសង្កេតឃើញលក្ខណៈទូទៅនៃរចនាសម្ព័ន្ធសំណង់ព្រះវិហារវត្តកំពូល ហាក់នៅរក្សាទម្រង់ដើម ជាពិសេសគឺរចនាសម្ព័ន្ធសំខាន់ៗនៃសំណង់នេះ។ កំពូលកណ្ដាលនៃដំបូលព្រះវិហារ កសាងខ្ពស់ត្រដែតស្រដៀងទៅនឹងកំពូលចេតិយធំៗក្នុងសំណង់សិល្បៈខ្មែរ ហើយអមដោយកំពូលតូចៗផ្សេងទៀតចំនួន ៤ នៅតាមជ្រុងនីមួយៗ។ ទម្រង់កំពូលនៅតាមជ្រុងទាំង៤នេះ ហាក់ដូចជាបន្ថយខ្នាត*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

*បន្តិចនៅថ្នាក់ទី២ និងបន្ថយខ្នាតតូចបំផុតនៅថ្នាក់ទី៣ នៃចុងថែងដំបូលខាងក្រោមបំផុត។ លក្ខណៈបែបនេះ គឺជាគំនិតសិល្បៈប្លែកមួយដែលពុំសូវឃើញមានច្រើនក្នុងសង្គមខ្មែរ ហើយពុំស្ថិតក្នុងការបែងចែកព្រះវិហារទាំង៤ប្រភេទ។[2] មិនតែប៉ុណ្ណោះ នៅតាមគល់កំពូលថ្នាក់ទី២ ភាគច្រើនមានសំណេរកត់ចំណាំខ្លីៗ។ ជ្រុងពាយ័ព្យមានពាក្យថា "**សាងព្រះវិហ៊ារនេះព្រះពុទ្ធសក្ក៉ាជកន្ល័ងទៅរហ្មើ ២៤៤២ឆ្នាំម**"។ ជ្រុងនិរតីមានពាក្យថា "**យើងខ្ញុំទំហ៊្យ ជាភិក្ខុ សាមណេរ មានចិត្រសាទ្ធាបានជួសជុលហួត(?) ព្រះវិហ៊ារនេះឡើងជាថ្មីយ៍ក្នុងឆ្នាំ... ព្រះពុទ្ធសក្ក៉ាជកន្ល័ងទៅរ២៤៦៧...**" ជាដើម។*

*ចំណែកឯការលម្អលើក្បាលសសរបាំងសាចជុំវិញព្រះវិហារ គេឃើញមានបន្ថែមរូបកិន្នរនិងគ្រុឌទ្រចុងដំបូលដូចការនិយមនៅតាមព្រះវិហារទូទៅដែរ (រូបលេខ៤)។ ចំពោះផ្ទៃកជុំវិញ ពុំមានការលម្អអ្វីឡើយ ពោលគឺជាជញ្ជាំងលាតធម្មតាដូចលំនាំដើម។ នៅផ្នែកខាងមុខនិងខាងក្រោយមានទ្វារម្ខាង២ ហើយនៅចំហៀងទាំងសងខាង មានតែបង្អួចម្ខាង៤ ប៉ុណ្ណោះ។ ប៉ុន្តែអ្វីដែលគួរឱ្យកត់ចំណាំនៃសំណង់ព្រះវិហារនេះ គឺនៅលើខឿនថ្នាក់ទី២ មានប្រវែង៩ម៉ែត្រស្មើជ្រុង ហើយក្បាច់លម្អប្រើជាបង្កាន់ដៃជុំវិញបាំងសាចគឺជាប្រភេទដីដុតរលោងពណ៌បៃតង (ខ្លះហៅថាសេរ៉ាមិច)។ ក្បាច់នីមួយៗមានទំហំប្រហែល៣តឹក៤ជ្រុង ហើយក្បាច់ខ្លះមានសណ្ឋានស្រដៀងនឹងលំនាំកាក់ចិន តែខ្លះមានរាងដូចផ្កា (រូបលេខ៥)។*




***រូបលេខ៤-៥ រចនាសម្ព័ន្ធនិងការលម្អផ្នែកដំបូលនៃព្រះវិហារវត្តកំពូល និងក្បាច់លម្អបង្កាន់ដៃខាងក្រៅ***

---

*[2] សូមអានបន្ថែម៖ ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-៣៦*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

នៅផ្នែកខាងក្នុងព្រះវិហារ គេរៀបចំសាងបាល័ង្កព្រះដីវ៍ធំនៅជាប់ជញ្ជាំងខាងលិចដូចព្រះវិហារទូទៅដែរ។ ព្រះបដិមាព្រះដីវ៍លាបទឹកមាស គង់ក្នុងកាយវិការផ្ចាញ់មារ។ ចន្លោះខាងមុខព្រះដីវ៍ មានសសរបេតុងធំៗ៤ជ្រុង ចំនួន៤ដើម ទ្រពិតានឈើ ដែលលើផ្ទៃពិតាននោះពុំមានគំនូរអ្វីគួរឱ្យកត់សម្គាល់ក្រៅក្បាច់លម្អធម្មតា និងរូបផ្កាភ្ញីផ្សេងៗ។ លើសសរទាំងអស់ គេគូរលម្អក្បាច់ភ្ញីដូចៗគ្នាទាំង៤ ជ្រុង ហើយដែលការលម្អនេះប្រហែលរៀបចំជួសជុលគូរថ្មី (រូបលេខ២៦)។ បើយោងតាមចំណារលើបាល័ង្កនោះបញ្ជាក់ថា កសាងព្រះបដិមា និងសន្ទិយា ព្រមទាំងជួសជុលពិតានព្រះវិហារនេះនៅក្នុងឆ្នាំ១៩៨១។

ចំពោះគំនូរលើជញ្ជាំងខាងក្នុងព្រះវិហារវត្តកំពូល ក៏ជាប្រភេទគំនូររៀបរាប់សាច់រឿងពុទ្ធប្រវត្តិ និងរឿងមហាវេស្សន្តរដូចបណ្ដាព្រះវិហារផ្សេងដែរ។ ប៉ុន្តែចំណុចពិសេសគួរឱ្យសង្កេត គឺព្រះវិហារវត្តកំពូលមានផ្ទៃជញ្ជាំងតូច៤ជ្រុងស្មើ ដែលវិចិត្រករត្រូវជ្រើសរើសអន្ទើសំខាន់ៗនៃសាច់រឿងមកគូរបង្ហាញ។ នៅជួរខាងក្រោម គេគូរសាច់រឿងមហាវេស្សន្តរ ដោយផ្ដើមចេញពីជ្រុងជញ្ជាំងទិសអាគ្នេយ៍ ព័ទ្ធមកខាងលិច ហើយបញ្ចប់នៅត្រឹមនគរកណ្ឌនៅជ្រុងជញ្ជាំងទិសឦសាន។

គំនូររឿងពុទ្ធប្រវត្តិ ចាប់ផ្ដើមនិងបញ្ចប់នៅលើជញ្ជាំងខាងកើត ទល់មុខនឹងបាល្ល័ង្កព្រះដីវ៍ តែផ្ទាំងគំនូរត្រង់ព្រះអង្គចាប់បដិសន្ធិ និងថ្វាយព្រះភ្លើងគួរជាប់គ្នានៅជួរខាងក្រោម ហើយគំនូរត្រង់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រឈួន បរិនិព្វាន និងចែកព្រះបរមសារីរិកធាតុ ស្ថិតនៅជួរខាងលើ (រូបលេខ២៧-៩)។ ចំណុចនេះ ហាក់ដូចជាបានបង្ហាញអ្នកមើលឱ្យច្បាស់ពីគំនិតកើត និងស្លាប់នៅកៀកក្បែរគ្នា។ រីឯគំនូរផ្សេងពីនេះក្នុងរឿងពុទ្ធប្រវត្តិ គឺវិចិត្រករបានសង្ខេបយកមកគូរបង្ហាញខ្លីៗដូចជា ប្រសូត្រ, សម្ដែងឫទ្ធិ, អភិសេក, ចេញបួស, ទទួលចង្ហាន់នាងសុជាតា, ផ្ចាញ់មារ, ប្រោសបញ្ចវគ្គីយ៍ភិក្ខុ, ប្រោសនាងពិម្ពា, ប្រោសពុទ្ធមាតានៅឋានត្រៃត្រិង្ស, មារអារាធនាព្រះអង្គចូលនិព្វាន, ទទួលចង្ហាន់នាយចុន និងទ្រង់ប្រឈួនជាដើម។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៦ បដិមាព្រះជីវ័ក្នុងព្រះវិហារវត្តកំពូល



រូបលេខ២៧ គំនូរព្រះអង្គទ្រង់ចូលនិព្វាន



រូបលេខ២៨ គំនូរថ្វាយព្រះភ្លើងព្រះបរមសព



រូបលេខ២៩ ត្រង់សុបិននិម្មិត (ចាប់បដិសន្ធិ)

ជាសេចក្តីសង្ខេប ព្រះវិហារវត្តកំពូលគឺជាស្ថាបត្យកម្មល្អប្លែកមួយក្នុងសំណង់វត្តអារាមខ្មែរ ដែលគេធ្លាប់ឃើញមានស្រដៀងនេះដូចជា ហោត្រៃវត្តស្វាយពពែ (រុះរើឆ្នាំ២០២១) និងព្រះវិហារវត្តស្វាយតាហែន (ស្រុកកងមាស ខេត្តកំពង់ចាម)។ មិនតែប៉ុណ្ណោះ បើផ្អែកតាមចំណារផ្សេងៗ ព្រះវិហារនេះកសាងក្នុងពុទ្ធសករាជ២៤២ (ឆ្នាំ១៨៩៩) ធ្លាប់ជួសជុលដំបូលក្នុងពុទ្ធសករាជ២៤៦៧ (ឆ្នាំ១៩២៤) និងជួសជុលផ្នែកផ្សេងៗទៀតជាបន្តបន្ទាប់នៅក្រោយសម័យសង្គ្រាម។ លើសពីនេះ បើផ្ទៀងផ្ទាត់ជាមួយឯកសារបារាំង គេអាចនិយាយបានថាទម្រង់ទូទៅនៃព្រះវិហារវត្តកំពូល គឺនៅរក្សាលំនាំដើមស្ទើរទាំងស្រុង៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០១៧, សំណង់នៅតាមវត្ត, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

Daniell Guéret & Dominique-Pierre Guéret

2017, The Khmer Pagoda, Kam editions

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត